ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## អាចនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ១០៧៧
ចុះថ្ងៃទី ៣១ _ ១២ _ ០៧
សាលដីកា
លេខ : ៩៧ "ខ"
ចុះថ្ងៃទី ២៣_០៧_០៩

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣-០៧-២០០៩ ដោយមានសមាសភាព ដូចខាងក្រោមៈ

ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ១០៧៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៧ ដែលមានៈ

- ជនជាប់ចោទឈ្មោះ [redacted] អិន ហៅ ម៉ៅ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ០៤-០១-២០០៥ ឃុំខ្លួនថ្ងៃទី ០៦-០១-២០០៥។

មានលោក គង់ ហេង ជាមេធាវីការពារ។

- ជនជាប់ចោទឈ្មោះ [redacted] ឡុងឌី ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរជួសជុលកង់ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ០៤-០១-២០០៥ ឃុំខ្លួនថ្ងៃទី ០៦-០១-២០០៥។

មានលោក [redacted] ហេង ជាមេធាវីការពារ។

ត្រូវជាប់ចោទពីបទ: ប្លន់ និងសម្លាប់មនុស្សដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភូមិតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ០២-០១-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted]។

- តាមបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] អិន ហៅ ម៉េ និងឈ្មោះ [redacted] ឡុងឌី ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៣ (ផ) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

<u>ដំណើររឿងមានដូចតទៅ:</u>

កាលពីថ្ងៃទី ០២-០១-២០០៥ វេលាម៉ោង ១៨ និង៣០នាទី នៅចំណុចផ្លូវលំ ភូមិសាស្ត្រ និងភូមិតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល មានក្រុមជនល្មើសមួយក្រុមមានគ្នា ៧នាក់ គឺ: ១. ឈ្មោះ [redacted] ម៉ៅ, ២. ឈ្មោះ [redacted] ឡុងឌី, ៣. ឈ្មោះ [redacted] យូហៃ, ៤. ឈ្មោះ [redacted] ចាន់ណា, ៥. ឈ្មោះ [redacted] ធី, ៦. ឈ្មោះ [redacted] ឆន និងបក្សពួកមិនស្គាល់ឈ្មោះ។ ក្រុមជនល្មើសទាំងនេះប្រដាប់ដោយដំបង, កាំបិតភ្នោត, កាំបិតសាំតឹម, កាំបិតតាំងតោ បានធ្វើមនុស្សឃាតគិតទុកជាមុន ដោយចាំពួនស្ទាក់សម្លាប់មនុស្សប្លន់យកម៉ូតូ របស់ជនរងគ្រោះឈ្មោះ [redacted] រដ្ឋារិទ្ធ មកពីរត់ម៉ូតូឌុប ពេលត្រឡប់មកផ្ទះវិញត្រូវជនល្មើសពួនស្ទាក់សម្លាប់ប្លន់យកម៉ូតូ សេ-១០០ កូរ៉េ ពណ៌ក្រហម លេខតួ ១៣៨៤៩១ លេខម៉ាស៊ីន ១៣៨៤៦៩៦។ លុះក្រោយកើតហេតុ នាថ្ងៃទី ០៤-០១-២០០៥ វេលាម៉ោង ១៧ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនជនល្មើសពីរនាក់ គឺឈ្មោះ [redacted] អិន និងឈ្មោះ [redacted] ឡុងឌី យកទៅកន្លែងប៉ុស្តិ៍រដ្ឋបាលតែម្តង។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៣ (ផ) ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោស:

ក. ឈ្មោះ [redacted] អិន

ខ. ឈ្មោះ [redacted] ឡុងឌី

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ០៤-០១-២០០៥។

គ. ឈ្មោះ [redacted] យូហៃ

ឃ. ឈ្មោះ [redacted] ឆន

ង. ឈ្មោះ [redacted] ធី

ច. ឈ្មោះ [redacted] ចាន់ណា

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ២០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទៈ ប្លន់ និងសម្លាប់មនុស្សដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភូមិតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ០២-០១-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- បង្គាប់ឱ្យជនជាប់ចោទទាំង ៦នាក់ខាងលើ រួមគ្នាសងសំណងថ្លៃម៉ូតូ ចំនួន ៤០០ដុល្លាអាមេរិក និងជម្ងឺចិត្ត ចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាត (ប្រពន្ធជនរងគ្រោះ)។

ក្នុងករណីរឹងរូស ត្រូវអនុវត្តតាមច្បាប់ដាក់គុកបង្ខំរូបរាងកាយដើម្បីទារប្រាក់ធនទណ្ឌ ។

៣- វត្ថុតាងនៅក្នុងសំណុំរឿងត្រូវរឹបអូសបំផ្លាញចោល ។

៤- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អ៊ិន, [redacted] ឡុងឌី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] យូហៃ, [redacted] ឆន, [redacted] ធី, [redacted] ចាន់ណា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] អ៊ិន ហៅ ម៉ៅ និងឈ្មោះ [redacted] ឡុងឌី ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៣ (ជ) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## <u>នាពេលសវនាការ</u>

ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] អ៊ិន និង [redacted] ឡុងឌី ឆ្លើយនៅតុលាការខេត្តកណ្តាល ។

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ្លើយនៅតុលាការខេត្តកណ្តាល ។

## <u>សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ</u>

១- ទទួលបណ្តឹងឧទ្ធរណ៍ របស់ជនជាប់ចោទឈ្មោះ [redacted] អ៊ិន និងឈ្មោះ [redacted] ឡុងឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៣ (ជ) ចុះថ្ងៃទី ១០-០៨-២០០៥ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ ។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវី</u>

រឿងនេះ មានអំពើល្មើសកើតឡើងមានជនល្មើស ៧នាក់ ហេតុអ្វីជនល្មើស ២នាក់នេះមិនរត់ រត់តែ ៥នាក់ បានន័យថា ពួកគាត់មិនបានប្រព្រឹត្ត ហើយថ្ងៃកើតហេតុ គឺគាត់បានទៅបុណ្យមែន ហើយគាត់មិនបានសារភាពថាបានប្រព្រឹត្តទេ ហើយជាក់ស្តែងបច្ចុប្បន្នមានការគំរាមកំហែងពីប៉ូលីស ។ ហើយកូនក្តីខ្លួនទទួលការបង្ខិតបង្ខំពីប៉ូលីសឱ្យឆ្លើយការគាបសង្កត់យកចម្លើយ បង្ខិតបង្ខំធ្វើទារុណកម្មលើកូនក្តីខ្លួន ។ ដូច្នេះ សុំតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ៖

- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

**<u>សាលាឧទ្ធរណ៍ភ្នំពេញ  យល់ឃើញថា:</u>**

១- បណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី ២៤-០៨-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] អិន ហៅ ម៉ៅ និងឈ្មោះ [redacted] ឡុងឌី ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

២- ជនជាប់ចោទ បានឆ្លើយសារភាពប្រហាក់ប្រហែលគ្នាថា: កាលពីថ្ងៃទី ០២-០១-២០០៥ វេលាម៉ោង ៥ និង ៣០នាទី បក្សពួកខ្លួនមាន ៧នាក់ បានបំបែកគ្នាទៅរកគោលដៅធ្វើសកម្មភាពប្លន់ ហើយក៏ទៅជួបជុំគ្នានៅចំណុចកើតហេតុដោយមានឈ្មោះ [redacted] អិន កាន់កាំបិតផ្គោត, [redacted] ឡុងឌី កាន់ដំបងឈើ, [redacted] យូហៃ កាន់កាំបិតសាំងតឹម, [redacted] កាន់កាំបិតសាំងតឹម, ប៊ុង កាន់កាំបិតតាំងតោ, ស្នា កាន់ដំបងឈើ និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ។ លុះដល់ម៉ោង ៦ និង ៣០ នាទីល្ងាច មានម៉ូតូមួយគ្រឿងមក ពួកខ្លួនក៏ស្ទុះសម្រុកចូលទៅវាយកាប់ចាក់ ហើយឈ្មោះ ប៊ុង ចាប់ជនរងគ្រោះអារក រួចនាំគ្នាអូសខ្មោចទម្លាក់ទឹកប្រឡាយ ។

ប៉ុន្តែតាមចម្លើយនៅចៅក្រមស៊ើបអង្កេត និងនៅសវនាការ ជនជាប់ចោទបានឆ្លើយបដិសេធវិញ ដោយអះអាងថា ពួកខ្លួនមិនបានធ្វើសកម្មភាពប្លន់ សម្លាប់មនុស្សយកម៉ូតូជនរងគ្រោះ កាលពីថ្ងៃទី ០២-០១-២០០៥ ដូចការចោទប្រកាន់ទេ ដោយប៉ូលីសគំរាមកំហែង និងវាយធ្វើបាប ។

៣- តាមចម្លើយឈ្មោះ [redacted] ស៊ីផាត, [redacted] សុផាត និង [redacted] សុធា ជានគរបាលស្រុកពញាឮថា ពេលយកចម្លើយឈ្មោះ [redacted] អិន និង [redacted] ឡុងឌី ប៉ូលីសពុំបានវាយដំ ឬគំរាមកំហែងទេ ហើយសួរនៅបន្ទប់ផ្សេងគ្នា ។

៤- ដូច្នេះចម្លើយបដិសេធរបស់ជនជាប់ចោទ គ្រាន់តែជាចម្លើយដោះសារ ក្នុងបំណងគេចវេសពីការទទួលខុសត្រូវចំពោះមុខច្បាប់នូវអំពើដែលខ្លួនបានប្រព្រឹត្តប៉ុណ្ណោះ ។

៥- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ពីបទ ប្លន់ និងមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភូមិតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ០២-០១-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ៣៣ (ជ) ចុះថ្ងៃទី ១០-០៨-២០០៥ របស់សាលាដំបូងខេត្តកណ្តាល សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ លើកលែងតែអត្ថបទច្បាប់គួរតែកែប្រែឱ្យបានត្រឹមត្រូវដូចការយល់ឃើញខាងលើ និងគួរលុបបិទានអនុវត្តដាក់គុកបង្ខំរូបរាងកាយដើម្បីទារប្រាក់ធនទណ្ឌចេញពីការប្រកាសនៃសាលក្រម ក្រៅពីនេះគួររក្សាទុកនៅដដែល ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី ២៤-០៨-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] អិន និងឈ្មោះ [redacted] ឡុងឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៣ (ជ) ចុះថ្ងៃទី ១០-០៨-២០០៥ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ លើកលែងតែអត្ថបទច្បាប់ត្រូវកែប្រែជា តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ វិញ និងលុបចោលវិធានអនុវត្តដាក់គុកបង្ខំរូបរាងកាយ ចេញពីការប្រកាសនៃសាលក្រម ក្រៅពីនេះរក្សាទុកនៅដដែល ។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទជាបន្តទៀត ។

៤- ដីកាស្វែងរកចាប់ខ្លួនលេខ ០៨០, ០៨១, ០៨២ និង ០៨៣ ចុះថ្ងៃទី ១៥-០៣-២០០៥ បង្គាប់ឱ្យស្វែងរកចាប់ខ្លួនឈ្មោះ [redacted] ឆន ហៅ ប៊ុង, [redacted] ចាន់ណា, [redacted] ធី និងឈ្មោះ [redacted] យូហៃ នៅតែមានសុពលភាពជានិច្ច រហូតដល់ពេលចាប់ខ្លួនជនជាប់ចោទទាំង ៤នាក់នេះ មកដាក់ឃុំបានជាស្ថាពរ ។

៥- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

<u>សាលដីកានេះចូលជាស្ថាពរ មានអានុភាពអនុវត្តតែលើឈ្មោះ [redacted] **ឡុងឌី** ក្រៅពីនោះពុំមានអានុភាពអនុវត្តឡើយ។</u>

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់៕

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted].[redacted] | ហត្ថលេខា: [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤
**ក្រឡាបញ្ជី**

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**

[redacted]